# មេរៀនទី៧៥៖ ភីលីពចែកចាយដំណឹងល្អ

## កិច្ចការ ៨៖២៦-៤០

**មេរៀនសម្រាប់គ្រូ** *(យូធូបលីង)*៖ https://youtu.be/m9UL67fgT-E

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/GMzDbAMFCY8

**គោលបំណង៖** ដើរតាមផ្លូវដែលព្រះបានដឹកនាំ។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ៣២៖៨** *“អញនឹងបង្ហាត់បង្រៀនឲ្យឯងស្គាល់ផ្លូវ ដែលឯងត្រូវដើរអញ នឹងទូន្មានឯង ដោយភ្នែកអញមើលឯងជាប់”* ។

**ចំរៀង** *(យូធូបលីង)*៖
១. ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0
២. ព្រះយេស៊ូវមករកមនុស្សមានបាប https://youtu.be/KuGfv2U0YmE
៣. បេសកកម្មដំណឹងល្អ https://youtu.be/T1WMFhM4Sxk

## ១. អធិស្ឋាន

## ២. ចំរៀង (រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)

## ៣. ល្បែងកំសាន្ត(១កាំ២កាំ)





១. គូសរង្វង់ ហើយរើសកុមារម្នាក់ធ្វើជាអ្នកចាំទី

២. ឲ្យកុមារទាំងអស់ឈរនៅក្នុងរង្វង់

៣.ហើយអ្នកចាំទីសួរ ១កាំ ២កាំ “សុំលេងផង” កុមារក្នុងរង្វង់និយាយថា “មិនឲ្យលេងទេ”អ្នកចាំទីសួរថា “ព្រោះអ្វី?” កុមារទាំងអស់ឆ្លើយថា “ប៉ាវចាញ់គេ ” អ្នកចាំទីសួរថា “ចាញ់កាលណា”កុមារទាំងអស់ឆ្លើយថា “ចាញ់ចូលឆ្នាំ” អ្នកចាំទីថា “គីឡូលេខប្រាំ” កុមារទាំងអស់និយាយ“កណ្តៀរស៊ីអស់” អ្នកចាំទីថា “ក្រៅឬក្នុង” ប្រសិនបើកុមារទាំងអស់រើសយក “ក្រៅ” គឺមានន័យថា អ្នកចាំទីត្រូវឈរចាប់កុមារលើខ្សែរង្វង់នៅពេលកុមារផ្សេងទៀត រត់ចូលក្នុងរង្វង់ បើអ្នកចាំទីចាប់បាននោះចាញ់ អ្នកចាំទីត្រូវចាំចាប់កុមារទាល់តែអស់ពីក្នុងរង្វង់ បើកុមារណារត់ចូលក្នុងរង្វង់បាននោះគេជាអ្នកឈ្នះ។

៤. បើកុមារទាំងអស់រើសយក “ក្នុង” ពួកគេត្រូវឈរនៅខាងក្នុង ហើយអ្នកចាំទីត្រូវលាតដៃចាប់ខាងក្នុងបើ អ្នកចាំទីចាប់បាននោះចាញ់។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាដូចជាយើងដែលត្រូវដើរតាមការដឹកនាំរបស់ព្រះ ហើយមិនថាការត់នៅខាងក្នុង ឬខាងក្រៅរង្វង់ទេ យើងគឺត្រូវដើរតាមការដឹកនាំរបស់ព្រះ។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់មានអារម្មណ៍ថា ព្រះបានប្រើអ្នកឲ្យធ្វើអ្វីមួយដែរឬទេ? តើអ្នកបានធ្វើការនោះទេ? ឬក៏អ្នកមិនអើពើនឹងវាទេ? ព្រះតែងតែដឹកនាំ និងបង្ហាញផ្លូវយើង ពេលខ្លះយើងមិនបានដឹងពីការបង្ហាញផ្លូវរបស់ព្រះ

ទេដោយសារយើងមិនបានយកចិត្តទុកដាក់ចំពោះព្រះ។ ពេលខ្លះទៀត យើងឮព្រះបន្ទូលតបរបស់ព្រះ តែមិន អើពើជាមួយព្រះអង្គ។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលបានដើរតាមការដឹកនាំរបស់ព្រះ ហើយបាន ចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវដល់សាសន៍ដទៃ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ភីលីពជាអ្នកអធិប្បាយព្រះបន្ទូលនៅក្នុងភូមិរបស់ សាសន៍សាម៉ារី គាត់កំពុងចែកចាយដំណឹងល្អពីព្រះ-យេស៊ូវទៅកាន់សាសន៍ សាម៉ារី។ ថ្ងៃមួយទេវតាបានមកជួបហ្វីលីព ហើយបានប្រាប់គាត់ថា ព្រះគម្ពីរ **កិច្ចការ ៨:២៦** “នោះទេវតានៃ ព្រះអម្ចាស់ មានព្រះបន្ទូលទៅភីលីពថា ចូរក្រោកឡើងទៅឯខាងត្បូងតាមផ្លូវ ដែលចុះពីក្រុងយេរូសាឡិម ទៅឯក្រុងកាសា ដែលជាទីរហោស្ថានទៅ” ។ ទេវតាមិនបានពន្យល់ពីមូលហេតុទេ ប៉ុន្តែភីលីពស្តាប់បង្គាប់ព្រះ។

នៅពេលនោះគាត់ឃើញមានសាសន៍អេធីយ៉ូពីម្នាក់(ដែលនៅទ្វីបអាហ្វ្រិក!) បានធ្វើដំណើរនៅក្បែរក្រុងយេរូសាឡិម។ គាត់មកក្រុងយេរូសាឡិមដើម្បីថ្វាយបង្គំព្រះ ទោះគាត់មិនមែនជាជនជាតិយូដាក៏ដោយ។ គាត់ដឹងថា ព្រះ ជាស្តេចពិត និងជាព្រះពិត។ ដូច្នេះគាត់ក៏អង្គុយនៅលើរថ របស់គាត់ដែលជារទេះអូសដោយសត្វសេះ។ គាត់បានអានព្រះគម្ពីរអេសាយ ហើយគាត់បានឆ្ងល់ពីអត្ថន័យក្នុងព្រះគម្ពីរមានន័យដូចម្តេច។

បន្ទាប់មកភីលីពបានរត់ឡើងរទេះសេះ ហើយបានពន្យល់ពីខគម្ពីរទៅកាន់សាសន៍អេធីយ៉ូពីនោះ។ ភីលីពបាន បង្រៀនខគម្ពីរដែលគាត់បានអានពីព្រះយេស៊ូវទៅកាន់បុរសម្នាក់នោះ។ បុរសសាសន៍ អេធីយ៉ូពីនោះមានអារម្មណ៍រីករាយណាស់ ហើយគាត់បានជឿអ្វីគ្រប់យ៉ាង ដែលភីលីពបានរៀបរាប់ប្រាប់។ គាត់ពោរពេញ ដោយអំណរនៅក្នុងព្រះអម្ចាស់ ហើយបានទទួលបុណ្យជ្រមុជទឹកតាមរយៈភីលីព! សាសន៍អេធីយ៉ូពី បានធ្វើដំណើរទៅផ្ទះដោយអំណរ និងសរសើរដំកើងព្រះយេស៊ូវ។

សាសន៍អេធីយ៉ូពីបានរៀនអំពីព្រះយេស៊ូវ ពីព្រោះភីលីពមិនខ្លាចក្នុងការដើរតាមការបង្ហាញផ្លូវរបស់ព្រះ។ ពេលខ្លះយើងមិនបានឆ្លើយតបគ្រប់យ៉ាងនោះទេ ប៉ុន្តែបើសិនជាយើងច្បាស់ថាវាជាការបង្ហាញផ្លូវរបស់ព្រះមែន យើងគួរតែមិនត្រូវភ័យខ្លាចក្នុងការដើរតាមការដឹកនាំរបស់ព្រះឡើយ។ តើថ្ងៃនេះព្រះដឹកនាំអ្នកដោយរបៀបណា? សូមយកចិត្តទុកដាក់ ពីព្រោះព្រះតែងតែដឹកនាំ និងបង្ហាញផ្លូវដល់យើងគ្រប់ៗគ្នា!

## ៦. សំនួរពិភាក្សា

១. តើសាសន៍ដទៃនោះមកពីណា? *(អេធីយ៉ូពី)*

២. តើភីលីពជួយបុរសសាសន៍អេធីយ៉ូពីដោយរបៀបណា? *(គាត់បានពន្យល់ពីខគម្ពីរ និងប្រាប់គាត់ ពីព្រះយេស៊ូវ)*

៣.តើហេតុផលអ្វីដែលធ្វើឲ្យបុរសសាសន៍អេធីយ៉ូពីមានអំណរ ពេលដែលគាត់ធ្វើដំណើរត្រឡប់ទៅអេធីយ៉ូពីវិញ? *(ពីព្រោះគាត់បានរៀនអំពីព្រះយេស៊ូវ)*

៤. តើអ្វីដែលនឹងកើតឡើងបើសិនភីលីពមិនបានដើរតាមការបង្ហាញផ្លូវរបស់ព្រះ? *(គាត់អាចនឹងបាត់បង់ឪកាសដើម្បីចែកចាយដំណឹងល្អពីព្រះយេស៊ូវទៅកាន់បុរសសាសន៍អេធីយ៉ូពីនោះ)*

៥. តើអ្នកនឹងធ្វើអ្វី ពេលដែលអ្នកដឹងថាព្រះសុំឲ្យអ្នកធ្វើអ្វីមួយ? *(សូមឲ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ច្រាំង ទន្លេ»



១.ឲ្យកុមារឈរជាជួរ២ ឬ៣ជួរទទឹងថ្នាក់រៀន។

២. ពន្យល់កុមារថា ពួកគេត្រូវលោតទៅក្រោយ ពេលដែលគ្រូស្រែកថា“ច្រាំង”។ ហើយនៅពេល ដែលគ្រូស្រែកថា“ទន្លេ” ពួកគេត្រូវលោតទៅមុខ។ គ្រូអាចនិយាយពាក្យដដែលៗជាប់ៗគ្នាក៏បាន។

៣. ប្រសិនបើកុមារណាម្នាក់ធ្វើខុសពីការណែនាំរបស់គ្រូគេនឹងត្រូវបញ្ឈប់ពីល្បែងនេះ។

៤.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងអាចស្តាប់បង្គាប់ព្រះដូចជាសាសន៍ អេធីយូពីដែលបានទទួលការសង្គ្រោះតាមរយៈដំណឹងល្អ និងបានទទួលបុណ្យជ្រមុជទឹកនៅក្នុងទន្លេ។

## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង ៣២៖៨** *“អញនឹងបង្ហាត់បង្រៀនឲ្យឯងស្គាល់ផ្លូវ ដែលឯងត្រូវដើរ អញនឹងទូន្មានឯង ដោយភ្នែកអញមើលឯងជាប់”* ។

## ៩. ហត្ថកម្ម «ភីលីពចែកចាយដំណឹងល្អ»

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម (ទំព័រខាងក្រោម) បន្ទះឈើ ស្កុតបិត និងកូល័រ ទៀន



១. ឲ្យក្រដាសហត្ថកម្មទៅកុមារម្នាក់១ច្បាប់ៗ

២. ឲ្យកុមារកាត់រទេះសេះ និងរូបទេសភាពផ្លូវ ហើយឲ្យកុមារផាត់ពណ៌រូបទាំងអស់។

៣. ឲ្យកុមារបិតបន្ទះឈើនៅខាងក្រោយរទេះសេះនោះ។

៤. ឲ្យកុមារកាត់គំនូសដាច់ៗនៅក្នុងរូប។

៥. កុមារអាចដាក់រូបរទេះសេះចូលទៅ ហើយធ្វើឲ្យវាផ្លាស់ទីបាននៅលើផ្លូវ។

## ១០. ចំរៀង (រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកធ្លាប់លឺសំលេងតូចមួយដាស់តឿនអ្នកក្នុងការនិយាយអ្វីមួយ ឬធ្វើអ្វីមួយដែរឬទេ? តើអ្នកឆ្លើយតបយ៉ាងដូចម្តេច? វាជាការល្បួងដែលព្រះវិញ្ញាណបរិសុទ្ធមិនចង់ឲ្យយើងធ្វើតាមវា។ ប៉ុន្តែតើវាជាអ្វីបើសិនជាភីលីពធ្វើអញ្ចឹងដែរ? សប្តាហ៍នេះ យើងនឹងស្តាប់ដោយយកចិត្តទុកដាក់-និងស្តាប់បង្គាប់ភ្លាមៗ - សូមឲ្យការបង្ហាញផ្លូវរបស់ព្រះបានស្ថិតជាប់នៅក្នុងចិត្តរបស់អ្នក។

**ហត្ថកម្ម៖** ចែកឲ្យកុមារម្នាក់មួយច្បាប់។ កុមារកាត់រទេះសេះ និងទិដ្ឋភាពផ្លូវ។ ឲ្យកុមារផាត់ពណ៌រូបភាពរបស់ពួកគេ។ បិតដំបងមួយនៅខាងក្រោយរទេះ។ កាត់បន្ទាត់ដាច់ៗដែលមាននៅលើផ្លូវ។ កុមារអាច បញ្ចូលរទេះហើយរំកិលវាតាមនៅលើផ្លូវ។ (សូមមើលគំរូខាងក្រោម)






# ភីលីពបានចែកចាយដំណឹងល្អពីព្រះយេស៊ូវ

